**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

# សេចក្តីជូនដំណឹង
# ស្តីពី
# វឌ្ឍនភាពនៃការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន ណាហ្គាវើលដ៍

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជម្រាបជូនសាធារណជន ឱ្យបានជ្រាបថា វិវាទការងាររួមនៅក្រុមហ៊ុន ណាហ្គាវើលដ៍ នេះ គឺផ្តើមចេញពីការរីករាលដាលនៃជំងឺកូវីដ-១៩ ដែលបានធ្វើឱ្យសកម្មភាពអាជីវកម្មមួយចំនួនក្នុងវិស័យទេសចរណ៍ សេវាកម្សាន្ត កាស៊ីណូ និងបដិសណ្ឋារកិច្ចនៅទូទាំងពិភពលោក ក៏ដូចជានៅប្រទេសកម្ពុជា ត្រូវបានផ្អាកសកម្មភាពអាជីវកម្ម ឬត្រូវរៀបចំដំណើរការឡើងវិញ ដោយត្រូវកាត់បន្ថយបុគ្គលិក និងអនុវត្តវិធានការសុខាភិបាល។ នៅខែមេសា ឆ្នាំ២០២១ ក្រុមហ៊ុនបានជូនដំណឹងដល់សហជីព និងប្រជុំជាមួយតំណាងកម្មករនិយោជិត អំពីគម្រោងកាត់បន្ថយបុគ្គលិកក្នុង ១២ផ្នែក ដែលមានចំនួន ១ ៣២៩នាក់ (ស្រី ៧៣៦នាក់) ក្នុងនោះ (ណាហ្គាវើលដ៍១ ចំនួន ៩៧៦នាក់ (ស្រី ៥១៨នាក់) និងណាហ្គាវើលដ៍២ ចំនួន ៣៥៣នាក់ (ស្រី ២១៨នាក់)។ ទន្ទឹមនឹងនេះ ក៏មានបុគ្គលិកចំនួន ២៩២នាក់ទៀត សុំលាឈប់ពីការងារ ដែលធ្វើឱ្យចំនួនកម្មករនិយោជិតត្រូវកាត់បន្ថយបានកើនដល់ ១ ៦២១នាក់។ យោងតាមសេចក្តីថ្លែងការណ៍ជាសាធារណៈរបស់ក្រុមហ៊ុន កាលពីថ្ងៃទី២៣ ខែមករា ឆ្នាំ២០២២ ក្រុមហ៊ុនមានកម្មករនិយោជិតសរុបចំនួន ៨ ៣៧១នាក់ ក្នុងនោះ មានសមាជិកសហជីពចំនួន ៣ ៩៧៦នាក់ ហើយក្រោយពីការកាត់បន្ថយ កម្មករនិយោជិតមានចំនួន ៦ ១៨១នាក់ ក្នុងនោះ សមាជិកសហជីពនៅសល់សរុបចំនួន ២ ៥៧២នាក់។

កម្មករនិយោជិតចំនួន ៣៧៣នាក់ ដែលជាសមាជិកសហជីព បានជំទាស់នឹងគម្រោងកាត់បន្ថយបុគ្គលិក ហើយទាមទារឱ្យក្រុមហ៊ុនទទួលយកខ្លួន និងអតីតបុគ្គលិកផ្សេងទៀតចូលធ្វើការវិញ រួមនឹងការទាមទារផ្សេងទៀត។

អនុវត្តតាមច្បាប់ស្តីពីការងារនិងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន ក្រសួងបាននិងកំពុងដោះស្រាយវិវាទការងារនេះ ចាប់តាំងពីទទួលពាក្យបណ្តឹងរហូតដល់បច្ចុប្បន្ន ដោយការទទួលការខុសត្រូវខ្ពស់ និងធានាផលប្រយោជន៍ស្របច្បាប់របស់ភាគីវិវាទបានចំនួន ៩លើក ប៉ុន្តែការផ្សះផ្សាមិនបានសះជា ដោយភាគីនិយោជកបន្តអនុវត្តតាមសេចក្តីបង្គាប់អាជ្ញាកណ្តាល រីឯភាគីសហជីពបានដាក់លក្ខខណ្ឌតម្រូវឱ្យនិយោជកត្រូវតែទទួលយកកម្មករនិយោជិតចំនួន ៣៧៣នាក់ ឱ្យចូលធ្វើការវិញ។

ឆ្លៀតក្នុងឱកាសនេះ ក្រសួងសូមជម្រាបជូនថា បន្ទាប់ពីទទួលបានពាក្យបណ្តឹងរបស់ភាគីកម្មករនិយោជិត នាយកដ្ឋានវិវាទការងារបានផ្សះផ្សាចំនួន ២លើក លើការទាមទារចំនួន ៥ចំណុច ដោយទទួលបានលទ្ធផលសះជា ១ចំណុច (ការអនុវត្តវិធានការសុខាភិបាល) និងមិនសះជាចំនួន ៤ចំណុច ហើយចំណុចមិនសះជាទាំង៤ នេះ ត្រូវបានបញ្ជូនទៅក្រុមប្រឹក្សាអាជ្ញាកណ្តាល ដើម្បីដោះស្រាយបន្ត នៅថ្ងៃទី២ ខែកក្កដា ឆ្នាំ២០២១។

ភាគីទាំងពីរបានជ្រើសរើសអាជ្ញាកណ្តាលដោយខ្លួនឯង និងប្រភេទសេចក្តីបង្គាប់មិនជាប់កាតព្វកិច្ច។ អាជ្ញា-កណ្តាលបានបើកសវនាការចំនួន ២លើក ហើយបានចេញសេចក្តីបង្គាប់លេខ០១២/២១ ណាហ្គាវើលដ៍ លីមីធីត ចុះថ្ងៃ



អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣) ៨៨ ៤៣ ៧៥ និងទូរសារ :(០២៣) ៨៨ ២៧ ៦៩

ទី១០ ខែកញ្ញា ឆ្នាំ២០២១ ( https://www.arbitrationcouncil.org/download/012-21-naga-world-limited/ ) ដែលមានខ្លឹមសារដូចខាងក្រោម៖

- ចំណុចវិវាទទី១ និងទី២៖
  - បដិសេធពិចារណាការទាមទាររបស់ភាគីកម្មករនិយោជិតឱ្យនិយោជកបញ្ឈប់គម្រោងកាត់បន្ថយកម្មករនិយោជិត ដែលកំពុងអនុវត្តនីតិវិធីបញ្ឈប់ពីការងាររួម។
- ចំណុចវិវាទទី៣៖
  - បង្គាប់ឱ្យនិយោជកអនុវត្តរបៀបគណនាប្រាក់បំណាច់អតីតភាពការងារ, សោហ៊ុយជំងឺចិត្ត, ប្រាក់រំលឹកអតីតភាពការងារមុនឆ្នាំ២០១៩, ប្រាក់បំណាច់ជួសការឈប់សម្រាកប្រចាំឆ្នាំ, និងប្រាក់បំណាច់ជួសការជូនដំណឹងមុនជូនកម្មករនិយោជិតឱ្យបានត្រឹមត្រូវតាមច្បាប់ ពេលបញ្ចប់កិច្ចសន្យាការងារ នៅចុងឆ្នាំ២០២០ និងដើមឆ្នាំ២០២១។
- ចំណុចវិវាទទី៤៖
  - បង្គាប់ឱ្យនិយោជកបន្តបើកប្រាក់បំណាច់អតីតភាពការងារឆ្នាំ២០២០ និងឆ្នាំ២០២១ ជូនកម្មករនិយោជិតនៅក្នុងឆ្នាំ២០២១ នេះបន្តទៀត
  - បដិសេធការទាមទាររបស់ភាគីកម្មករនិយោជិតឱ្យនិយោជកបន្តការផ្តល់ជូនប្រាក់រំលឹកអតីតភាពការងារមុនឆ្នាំ២០១៩ ជូនកម្មករនិយោជិត
  - បង្គាប់ឱ្យនិយោជកគណនាប្រាក់បំណាច់អតីតភាពការងារឆ្នាំ២០២០ និងឆ្នាំ២០២១ ឱ្យបានត្រឹមត្រូវតាមច្បាប់ជូនកម្មករនិយោជិត
  - បដិសេធការទាមទាររបស់កម្មករនិយោជិតឱ្យនិយោជកគណនាប្រាក់រំលឹកអតីតភាពការងារមុនឆ្នាំ២០១៩ ឱ្យបានត្រឹមត្រូវតាមច្បាប់ជូនកម្មករនិយោជិត។

- ភាគីនិយោជកបានអនុវត្តសេចក្តីបង្គាប់អាជ្ញាកណ្តាល៖
  - ផ្តល់ជូនបុគ្គលិកនូវប្រាក់សំណងបញ្ចប់កិច្ចសន្យាការងារប្រសើរជាងច្បាប់
  - បន្តទូទាត់ប្រាក់បំណាច់បញ្ចប់កិច្ចសន្យាការងារជូនបុគ្គលិកដែលត្រូវបានបញ្ឈប់ ស្របតាមច្បាប់ស្តីពីការងារ
  - បើកប្រាក់បំណាច់អតីតភាពការងារជូនកម្មករនិយោជិតឡើងវិញស្របតាមច្បាប់ស្តីពីការងារ។

- ភាគីកម្មករនិយោជិត៖
  - បានប្តឹងជំទាស់សេចក្តីបង្គាប់អាជ្ញាកណ្តាល
  - បានជូនដំណឹងទៅនិយោជក និងចម្លងជូនក្រសួងពីការធ្វើកូដកម្មនៅមុខក្រុមហ៊ុនចាប់ពីថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០២១ ដើម្បីទាមទាររហូតដល់ចំនួន ៩ចំណុច ដូចខាងក្រោម៖
    ១. ទាមទារឱ្យក្រុមហ៊ុនទទួលយកថ្នាក់ដឹកនាំសហជីព សមាជិកប្រតិភូបុគ្គលិក និងកម្មករនិយោជិតចំនួន ៣៧៣នាក់ ដែលមិនព្រមទទួលយកសំណងបញ្ចប់កិច្ចសន្យាការងារ ចូលបម្រើការងារនៅកន្លែងដើមវិញ រួមទាំងផ្តល់ប្រាក់រំលឹកផ្សេងៗ គិតតាំងពីថ្ងៃបញ្ឈប់រហូតដល់ថ្ងៃចូលធ្វើការវិញ
    ២. ទាមទារឱ្យក្រុមហ៊ុន គិតប្រាក់បំណាច់បញ្ចប់កិច្ចសន្យាការងារបង្គ្រប់បន្ថែមឱ្យបានត្រឹមត្រូវសម្រាប់កម្មករនិយោជិត ដែលត្រូវបានកាត់ចេញតាមគម្រោងកាត់បន្ថយបុគ្គលិក និងព្រមទទួលយកសំណងរបស់ក្រុមហ៊ុនក្នុងអំឡុងខែមេសា និងខែបន្តបន្ទាប់ក្នុងឆ្នាំ២០២១ ព្រមទាំងរក្សាកន្លែងការងារឱ្យពួកគាត់រយៈពេល ២ឆ្នាំ ដោយអនុលោមតាមមាត្រា៩៥ នៃច្បាប់ស្តីពីការងារ និងសេចក្តីបង្គាប់របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០១២/២១ ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០២១ ត្រង់ចំណុចវិវាទទី៣

៣. ទាមទារឱ្យក្រុមហ៊ុនអនុវត្តសេចក្តីបង្គាប់របស់អាជ្ញាកណ្តាលលេខ០១២/២១ ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០២១ ត្រង់ចំណុចវិវាទទី៣ ដោយគិតប្រាក់បញ្ចប់កិច្ចសន្យាការងារបង្រួបបន្ថែមឱ្យបានត្រឹមត្រូវ សម្រាប់កម្មករនិយោជិត ដែលត្រូវបានបញ្ឈប់មិនត្រឹមត្រូវតាមច្បាប់ស្តីពីការងារ ក្នុងអំឡុងចុងឆ្នាំ ២០២០ និងដើមឆ្នាំ២០២១

៤. ទាមទារឱ្យក្រុមហ៊ុនផ្តល់ប្រាក់បំណាច់អតីតភាពការងារ និងប្រាក់រំលឹកអតីតភាពការងារឱ្យបានត្រឹមត្រូវ តាមច្បាប់សម្រាប់ឆ្នាំ២០២០ និងឆ្នាំ២០២១ ដូចបានចង្អុលបង្ហាញពីរបៀបគណនាប្រាក់បំណាច់ក្នុង ចំណុចវិវាទទី៣ នៃសេចក្តីបង្គាប់របស់អាជ្ញាកណ្តាលលេខ០១២/២១ ចុះ ថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០២១

៥. ទាមទារឱ្យក្រុមហ៊ុនផ្តល់ប្រាក់បន្ថែមស្មើនឹង ៧% (ប្រាំពីភាគរយ) លើប្រាក់ឈ្នួលគោលបច្ចុប្បន្នឱ្យ កម្មករនិយោជិតទាំងអស់ ដើម្បីបំពេញអតិផរណាតម្លៃទំនិញលើទីផ្សារក្នុងឆ្នាំ២០២០ និងឆ្នាំ២០២១

៦. ទាមទារឱ្យក្រុមហ៊ុនបញ្ឈប់ការគេងប្រវ័ញ្ច តាមរយៈការប្រើប្រាស់កម្មករនិយោជិតក្រោមស្លាកកម្មសិក្សា និងប្តូរពួកគាត់ឱ្យក្លាយជាកម្មករនិយោជិតពេញសិទ្ធិដូចកម្មករនិយោជិតផ្សេងៗទៀត។ សម្រាប់កម្មករ និយោជិតដែលក្រុមហ៊ុនបានបញ្ចប់កិច្ចសន្យាកម្មសិក្សាកន្លងមក ហើយពួកគាត់មិនព្រមទទួលយកការ បញ្ចប់កិច្ចសន្យានេះ ក្រុមហ៊ុនត្រូវបន្តកិច្ចសន្យាការងារឱ្យពួកគាត់ជាបុគ្គលិកពេញសិទ្ធិវិញ។ ដោយឡែក សម្រាប់កម្មករនិយោជិតកម្មសិក្សាដែលព្រមទទួលយកការបញ្ចប់កិច្ចសន្យា ក្រុមហ៊ុនត្រូវទូទាត់ប្រាក់ បំណាច់និងអត្ថប្រយោជន៍ផ្សេងៗឱ្យបានត្រឹមត្រូវតាមច្បាប់

៧. ទាមទារឱ្យក្រុមហ៊ុនពិនិត្យឡើងវិញ លើការទាមទារដកប្រធានផ្នែកកាស៊ីណូ

៨. ទាមទារឱ្យក្រុមហ៊ុនអនុវត្តសេចក្តីបង្គាប់របស់អាជ្ញាកណ្តាលលេខ៤៧/០៩ ចុះថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០០៩ ត្រង់ចំណុចវិវាទទី៤ ដោយផ្តល់ប្រាក់ឈ្នួលគោលស្មើគ្នាដល់កម្មករនិយោជិត ដែលជាជន ជាតិខ្មែរ និងកម្មករនិយោជិតដែលជាជនជាតិបរទេសដែលមានឋានៈដូចគ្នា

៩. ទាមទារឱ្យក្រុមហ៊ុនអនុវត្តសេចក្តីបង្គាប់អាជ្ញាកណ្តាល៖

- លេខ១០/១០ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១០ ត្រង់ចំណុចវិវាទទី២ ឱ្យទទួលយកអតីតថ្នាក់ដឹកនាំ សហជីព និងប្រតិភូបុគ្គលិកចំនួន ៤នាក់ ចូលធ្វើការវិញនិងគិតប្រាក់រំលឹកនិងប្រាក់អត្ថប្រយោជន៍ ពាក់ព័ន្ធផ្សេងទៀត
- លេខ០៧៨/១០ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១០៖
  ក-ចំណុចវិវាទទី២៖ទទួលយកអតីតកម្មករនិយោជិតចំនួន ២នាក់ ចូលបម្រើការងារនៅកន្លែង ដើមវិញ និងផ្តល់ប្រាក់រំលឹកចាប់ពីថ្ងៃបញ្ឈប់រហូតដល់ថ្ងៃចូលធ្វើការវិញរួមទាំងប្រាក់អត្ថប្រយោជន៍ ផ្សេងៗទៀត
  ខ-ចំណុចវិវាទទី៣៖ ផ្តល់ប្រាក់បញ្ចប់កិច្ចសន្យាបង្រួបបន្ថែមតាមច្បាប់ឱ្យកម្មករនិយោជិតចំនួន ១៨នាក់
- លេខ១៨៤/២០១២ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១២ ត្រង់ចំណុចវិវាទទី១ដោយផ្តល់ប្រាក់បំណាច់ បញ្ចប់កិច្ចសន្យាឱ្យបានត្រឹមត្រូវដល់អតីតកម្មករនិយោជិតចំនួន ៣នាក់
- លេខ០២៨/១៤ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៤ ត្រង់ចំណុចវិវាទទី២ និងទី៣ ដែលមានអតីតកម្មករ និយោជិតបានទទួល និងមិនបានទទួលប្រាក់បំណាច់ត្រឹមត្រូវតាមច្បាប់ចំនួន ៨នាក់។

ចំណុចទាមទារទាំង៩ ខាងលើ មានចំណុចជាច្រើនជាចំណុចទាមទារថ្មីដែលមិនមាននៅក្នុងសេចក្តីបង្គាប់ អាជ្ញាកណ្តាលលេខ០១២/២១ ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០២១ ឡើយ។ យោងតាមស្មារតីនៃមាត្រា៣១៩ និង មាត្រា៣២០ នៃច្បាប់ស្តីពីការងារ មានតែចំណុចដែលឆ្លងកាត់ការដោះស្រាយនៅក្រុមប្រឹក្សាអាជ្ញាកណ្តាលរួច ទើប អាចក្លាយជាកម្មវត្ថុនៃការធ្វើកូដកម្មបាន។

បន្ទាប់ពីទទួលបានសំណើរបស់និយោជក នៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២១ សាលាដំបូងរាជធានីភ្នំពេញបានចេញដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន ដោយហាមឃាត់ការធ្វើកូដកម្មរបស់កម្មករនិយោជិតក្រុមហ៊ុន ណាហ្គាវើលដ៍ ដែលគ្រោងនឹងប្រព្រឹត្តទៅចាប់ពីថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០២១ តទៅ និងកំណត់ថាកម្មករនិយោជិតដែលនៅតែបន្តធ្វើកូដកម្មដោយផ្ទុយនឹងខ្លឹមសារនៃសេចក្ដីសម្រេចនេះ ត្រូវកំណត់គុណវុឌ្ឍិថាជាកូដកម្មខុសច្បាប់ និងត្រូវចាត់ទុកជាកំហុសធ្ងន់ធ្ងរ។ កម្មករនិយោជិតបានធ្វើកូដកម្មនៅព្រឹកថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០២១ ទោះបីជាអាជ្ញាសាលានៃសាលាដំបូងរាជធានីភ្នំពេញ បានប្រកាសដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ននៅចំពោះមុខក្រុមអ្នកតវ៉ា ហើយតំណាងអ្នកតវ៉ាក៏បានចុះហត្ថលេខាលើកំណត់ហេតុអនុវត្តដីកាសម្រេច។

ចាប់ពីថ្ងៃទី១៨ ដល់ថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២១ ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ តាមរយៈគណៈកម្មការសម្រាប់ដោះស្រាយបញ្ហាកូដកម្ម បាតុកម្មនៅតាមគ្រប់មុខសញ្ញា បានអញ្ជើញភាគីវិវាទមកចរចាបានចំនួន ៧លើក ដើម្បីស្វែងរកលទ្ធភាពសម្របសម្រួលបន្តស្របតាមច្បាប់ស្ដីពីការងារ។ ភាគីកម្មករនិយោជិតនៅតែបន្តទាមទារឱ្យក្រុមហ៊ុនត្រូវតែទទួលយកកម្មករនិយោជិតចំនួន ៣៧៣នាក់ ឱ្យចូលធ្វើការវិញជាដាច់ខាតដដែល ទើបពិភាក្សាលើចំណុចទាមទារដទៃផ្សេងទៀត។

តបតាមការសម្របសម្រួលដោះស្រាយរបស់ក្រសួង មានបងប្អូនអតីតបុគ្គលិកជាបន្តបន្ទាប់បានយល់ព្រមទទួលយកការទូទាត់ប្រាក់បំណាច់បញ្ចប់កិច្ចសន្យាការងារជាមួយក្រុមហ៊ុន ដែលគិតមកដល់ថ្ងៃទី៩ ខែមីនា ឆ្នាំ២០២២ នេះ មានអតីតបុគ្គលិកចំនួន ១៤៧នាក់ ក្នុងចំណោម ៣៧៣នាក់ ទទួលយកការទូទាត់ ដែលធ្វើឱ្យចំនួនអតីតបុគ្គលិកដែលមិនព្រមទទួលយកសំណងនៅសល់ត្រឹមតែ ២២៦នាក់ប៉ុណ្ណោះ។

ជាថ្មីម្ដងទៀត ដោយផ្អែកតាមនីតិវិធីជាធរមានដែលមានកំណត់នៅក្នុងច្បាប់និងក្នុងគោលបំណងឈានទៅបញ្ចប់ករណីវិវាទនេះដោយសន្តិវិធី ក៏ដូចជាដើម្បីរក្សាបាននូវផលប្រយោជន៍របស់ភាគីកម្មករនិយោជិត ភាគីនិយោជក និងដើម្បីរួមចំណែកក្នុងការរក្សាផលប្រយោជន៍សាធារណៈ ក្រសួងសូមអំពាវនាវដល់បងប្អូនបាតុករដែលជាអតីតបុគ្គលិក និងបុគ្គលិករបស់ក្រុមហ៊ុន ណាហ្គាវើលដ៍ ដែលបានចូលរួមធ្វើបាតុកម្មដោយអវត្តមានពីកន្លែងការងារ សូមបញ្ឈប់នូវសកម្មភាពដែលបង្កជាកំហុសនាំឱ្យប៉ះពាល់ដល់ផលប្រយោជន៍ស្របច្បាប់របស់ខ្លួន។ ក្រសួងនឹងបន្តសហការជាមួយស្ថាប័នពាក់ព័ន្ធ ដើម្បីដោះស្រាយរាល់កង្វល់នានារបស់បងប្អូនបាតុករ ក៏ដូចជាគិតគូរផងដល់សិទ្ធិស្របច្បាប់របស់វិនិយោគិនផងដែរ។

ទន្ទឹមនឹងនេះ សូមបងប្អូនកម្មករនិយោជិតអនុវត្តឱ្យបានខ្ជាប់ខ្ជួននូវវិធានការសុខាភិបាល "៣កុំ ៣ការពារ" ដើម្បីចូលរួមទប់ស្កាត់ការឆ្លងរាលដាលជំងឺកូវីដ-១៩ បំប្លែងខ្លួនថ្មី អូមីក្រុង។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម សាធារណជន ជ្រាបតាមការគួរ។

ថ្ងៃព្រហស្បតិ៍ ៨កើត ខែផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី១០ ខែមីនា ឆ្នាំ២០២២